# ក្រសួងកិច្ចការនារីបង្ហាញពីរបៀបទាក់ទាញថវិកាសម្រាប់គម្រោងបញ្ជ្រាបយេនឌ័រ

ឃួន លក្ខិណា

**ភ្នំពេញ :** ដោយមានការបារម្ភទៅលើថវិកាសម្រាប់ប្រើប្រាស់ក្នុងគម្រោងបញ្ជ្រាបយេនឌ័ររបស់ជាតិមានចំនួនតិចតួច ក្រសួងកិច្ចការនារីបានធ្វើការណែនាំដល់មន្ត្រីតាមក្រសួងស្ថាប័ននានាក្នុងកិច្ចប្រជុំកាលពីព្រឹកថ្ងៃចន្ទនេះ អំពីរបៀបធ្វើគម្រោងផែនការសម្រាប់ទាញយកថវិកាជាតិមកប្រើប្រាស់ក្នុងការឆ្លើយតបនឹងតម្រូវការយេនឌ័រនាពេលបច្ចុប្បន្ន។

ក្នុងសិក្ខាសាលា កាលពីព្រឹកថ្ងៃចន្ទធ្វើនៅសណ្ឋាគារភ្នំពេញ ក្រសួងកិច្ចការនារីបានអញ្ជើញលោកស្រីបណ្ឌិត រៀលណា អ៊ីឈិ សាស្ត្រាចារ្យនៃវិទ្យាស្ថាន RMIT ប្រទេសអូស្ត្រាលី មកបង្ហាត់បង្ហាញអំពីរបៀបរៀបចំផែនការស្នើសុំថវិកាជាតិដែលសមស្របនឹងតម្រូវការយេនឌ័រទៅដល់មន្ត្រីមកពីក្រសួងស្ថាប័ននានា និងនៅរាជធានីភ្នំពេញ។

លោកស្រី ច័ន្ទ សូរីយ៍ រដ្ឋលេខាធិការក្រសួងកិច្ចការនារីថ្លែងឲ្យដឹងថា ក្រសួងបានរៀបចំសិក្ខាសាលានេះបីវគ្គហើយក្រោមការឧបត្ថម្ភពី UNDP និងបណ្ដុះបណ្ដាលមន្ត្រីក្រសួងសេដ្ឋកិច្ច ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងការងារ។

លោកស្រីបន្តថា កម្ពុជាជាប្រទេសក្រីក្រ ដូច្នេះថវិកាជាតិមានកម្រិត។ រីឯការរៀបចំថវិកាប្រចាំឆ្នាំនៅតែមានភាពស្មុគស្មាញ ដោយសារតែគ្រប់វិស័យសុទ្ធតែជាអាទិភាព ខណៈថវិកាជាតិមានតិចនាំឲ្យមានការលំបាកក្នុងការចាត់ចែង។ លោកស្រីបន្តថា៖«ការងារបញ្ជ្រាបយេនឌ័រនេះ ក៏ជាផ្នែកមួយអាទិភាពដែរ ដូច្នេះ មន្ត្រីទាំងអស់ត្រូវតែមានទេពកោសល្យ ចេះធ្វើផែនការ ចេះធ្វើគម្រោង ដើម្បីទាញយកថវិកាមកប្រើប្រាស់នៅក្នុងការងារក្នុងវិស័យរបស់ខ្លួន»។ លោកស្រីបន្តថា គម្រោងនេះនឹងយកទៅអនុវត្តនៅតាមស្ថាប័ននានា និងតាមតំបន់គោលដៅផងដែរ។

លោកស្រី អាយ៉ា យ៉ាម៉ាគូឈិ ប្រធានក្រុមការងារគម្រោង PGM2 បានថ្លែងថា លោកស្រីរៀលណា អ៊ីឈិ នឹងចែករំលែកបទពិសោធការងារនេះ ពីរបៀបសរសេរគម្រោងផែនការល្អ សម្រាប់ទាក់ទាញថវិកាមកបម្រើឲ្យការងារបញ្ជ្រាបយេនឌ័រនៅគ្រប់ផ្នែក។ លោកស្រីថា៖«ខ្ញុំគិតថា សម្រាប់ថវិកាដែលឆ្លើយតបនិងការបញ្ជ្រាបយេនឌ័រ គឺជាទស្សនទានថ្មីសម្រាប់អ្នកទាំងអស់គ្នា ប៉ុន្តែវាគឺជាយុទ្ធសាស្ត្រសម្រាប់ធ្វើឲ្យមានការបញ្ជ្រាបយេនឌ័រក្នុងសង្គមដែរ»។

លោកស្រី បណ្ឌិត រៀលណា អ៊ីឈិ សាស្ត្រាចារ្យនៃវិទ្យាស្ថាន RMIT នៅប្រទេសអូស្ត្រាលី បានលើកឡើងថា៖«ខ្ញុំនឹងចែករំលែកបទពិសោធ ចំណេះដឹងរបស់ខ្ញុំទៅឲ្យអ្នកទាំងអស់គ្នា ទោះជាខ្ញុំមិនបានដឹងអំពីដំណើរការរៀបចំថវិកាក្នុងប្រទេសកម្ពុជា និងការរៀបចំផែនការរបស់ក្រសួងនីមួយៗក្ដី តែវាជាការចែករំលែកចំណេះដឹងអំពីរបៀបធ្វើផែនការដើម្បីអនុវត្តនៅក្នុងប្រទេសនីមួយៗ»។ លោកស្រីសង្ឃឹមថា អ្នកចូលរួមនឹងយល់ដឹងពីក្របខ័ណ្ឌធ្វើផែនការ និងឧបករណ៍នៃការវិភាគសម្រាប់រៀបចំថវិកាឆ្លើយតបនឹងបញ្ហាយេនឌ័រនេះ៕ ■